

# កីឡាការនីបាញ់ធ្នូ

Alyson Curro

Nan Hom Noon

Let's Read

The Asia Foundation



មានក្មេងស្រីម្នាក់មកពីរដ្ឋកាឈិន ឈ្មោះ អុង ង្គេន។ នាង
ចូលចិត្តលេងកីឡាបាញ់ធ្នូ ដែលជាប្រភេទកីឡាមួយយ៉ាងតម្រូវ
ឱ្យបាញ់ព្រួញពីធ្នូទៅកាន់គោលដៅ។
ពេលមានធ្នូនិងព្រួញក្នុងដៃ អុង ង្គេន មានអារម្មណ៍ថាខ្លួនឯង
មានសមត្ថភាពខ្លាំងពូកែ។



ពេល អូង ង្គេន អាយុ ១៧ ឆ្នាំ នាងបានផ្លាស់ទីលំនៅមកទីក្រុង
រ៉ង់ហ្គូន ដើម្បីហ្វឹកហាត់បាញ់ធ្នូជាមួយសហព័ន្ធកីឡាបាញ់ធ្នូ
មីយ៉ាន់ម៉ា។

នាងបានហ្វឹកហាត់យ៉ាងខ្លាំង ហើយបានរៀនច្រើនពី
ការប្រើប្រាស់ធ្នូ ដូចជានាងចេះគ្រប់គ្រងជំហាន ល្បឿន និង
ពេលវេលា។

លើសពីនេះ នាងក៏ស្ទាត់ក្នុងការតម្រង់ឱ្យចំគោលដៅ និងបាញ់
ព្រួញ។ អូង ង្គេន បានសាកល្បងធ្នូជាច្រើនប្រភេទ ហើយនាង

ចូលចិត្តផ្ទះផ្កាំ ដែលមានឃ្លី និងខ្សែរ៉កច្រើន។




ពីរឆ្នាំក្រោយមក អូង ង្គេន ចាប់ផ្ដើមប្រកួតជាលក្ខណៈ
អន្តរជាតិ។ វាគឺជារឿងសំខាន់ ដោយ អូង ង្គេន គ្រាន់តែជា
ក្មេងស្រីម្នាក់មកពីភូមិតូចមួយនៅប្រទេសមីយ៉ាន់ម៉ា។

ឥឡូវនាងត្រូវតំណាងប្រទេសរបស់ខ្លួនទៅកាន់ពិភពលោក
ទាំងមូល។ ប៉ុន្តែ អូង ង្គេន មិនបានយកឈ្នះក្នុងការប្រកួតទាំង
នេះភ្លាមៗទេ។ នាងចាប់ផ្ដើមមានការខកចិត្តហើយពេលខ្លះ
នាងមានអារម្មណ៍ថាចង់ឈប់លេងកីឡាបាញ់ធ្នូនេះទៀតផង។



គ្រួសារនាង ព្រមទាំងគ្រូបង្វឹក បានលើកទឹកចិត្តនាងកុំឱ្យបោះបង់។
ទីបំផុត អួង ង្គេន ខិតខំហ្វឹកហាត់ឡើងវិញ។ នាងបានទៅទីលានហាត់បាញ់ធ្នូ ហើយហ្វឹកហាត់ ៥ ម៉ោងក្នុងមួយថ្ងៃ។



បួនឆ្នាំក្រោយមក ការខិតខំប្រឹងប្រែងរបស់ អូង ង្គេន បាន ទទួលជោគជ័យ។ នាងបានឈ្នះមេដាយមាសដំបូងរបស់នាង ក្នុងកម្មវិធី អាស៊ីគ្រេនព្រីឆ្នាំ២០០៨!

នៅពេលនាងអាយុ២៨ឆ្នាំ អូង ង្គេន បានឈ្នះមេដាយអន្តរជាតិ ជាច្រើន។

ក្នុងឆ្នាំ២០១៣ នាងបានឈ្នះពានរង្វាន់កីឡាឆ្នើមរបស់ ប្រធានាធិបតី។

អូង ង្គេន ធ្លាប់ទទួលបរាជ័យជាច្រើនដង មុនក្លាយជាជើងឯក។ ដោយសារការខិតខំប្រឹងប្រែង និងភាពអំណត់ ទើបធ្វើឱ្យនាងក្លាយជាកីឡាការនីឯកផ្នែកកីឡាបាញ់ធ្នូនៅប្រទេសមីយ៉ាន់ម៉ា និងពិភពលោក។



ចូរសរសេររឿងផ្ទាល់ខ្លួនរបស់ប្អូន។
តើពេលណាដែលប្អូនសប្បាយចិត្តជាងគេ?
តើប្អូនចូលចិត្តធ្វើអ្វី?

ពេលខ្លះ ជីវិតតែងជួបឧបសគ្គ។
ចូរប្អូននិយាយពីឧបសគ្គ ដែលប្អូនបានជួបប្រទះ។
ចូរប្អូននិយាយពីគម្រោងនាពេលអនាគតរបស់ប្អូន។ តើប្អូនចង់ប្រកបអាជីពអ្វី?



ចូរគូររូបរបស់ប្អូន។

Brought to you by

The Asia Foundation

Let’s Read is an initiative of The Asia Foundation’s Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*The Archer*, Author: Alyson Curro. Illustrator: Nan Hom Noon. Published by The Asia Foundation - Let’s Read, © The Asia Foundation - Let’s Read. Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2020. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by/4.0/
Contributing translators: Somey Chheang